ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
18 / 11 / 2016
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ច័ន្ទ ទី ១០ ខែ តុលា ឆ្នាំ ២០១៦

**សវនាការលើភ័ស្តុតាង - ថ្ងៃ ៤៦១**

រៀបចំដោយ៖ កញ្ញា **ជា ស៊ីវហ័ង** និង កញ្ញា Stavroula PAPADOPOULOS

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ |
| ចៅក្រមបំរុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin Karopkin |
| ក្រឡាបញ្ជី ៖ កញ្ញា ជា ស៊ីវហ័ង, និង កញ្ញា Stavroula PAPADOPOULOS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, និង លោក Nicholas KOUMJIAN |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD និង លោក |

| |
|---|
| វេន ពៅ |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ អ្នកជំនាញ លោកស្រី Peggy LEVINE (2-TCE-81) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្នូរ សុផ្លារី |
| ផ្សេងៗ៖ លោក វ៉ាត សុម៉ៅ, លោកស្រី យស សិរីរ័ត្ន, លោក ឡូញ ង៉ែត, លោក មៀច សុវណ្ណា, លោក ខៀវ ម៉ានី, កញ្ញា Aureliarita MARCELLUS |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ១០.០៦ | បញ្ចប់ម៉ោង៖ ១៦.០២ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣៦ | បញ្ចប់ម៉ោង៖ ១១.០៨ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣២ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤២ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៣ ម៉ោង និង ៥ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ១០.០៧ | ១០.០៧ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ | ១០.០៧ | ១០.០៩ |
| សារណាផ្ទាល់មាត់របស់សហមេធាវីនាំមុខស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកសម្រង់នៃសៀវភៅដែលនិពន្ធដោយអ្នកជំនាញ 2-TCE-81 | សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន<br><br>អង្គជំនុំជម្រះ | ១០.១០<br>១០.១៣<br>១០.១៤<br>១០.១៥<br>១០.១៦<br>១០.១៦ | ១០.១៣<br>១០.១៤<br>១០.១៥<br>១០.១៥<br>១០.១៧<br>១០.១៦ |

| | | | |
|---|---|---|---|
| សារណាផ្ទាល់មាត់របស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យអង្គ ជំនុំជម្រះទទួលយកឯកសារចំនួនពីរពាក់ព័ន្ធនឹងអ្នកជំនាញ 2-TCE-81 | មេធាវីការពារក្តី ខៀវ សំផន<br><br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១០.១៧<br>១០.២១<br>១០.២០<br>១០.២១<br>១១.០៨ | ១០.២០<br>១០.២១<br>១០.២០<br>១០.២១<br>១១.១១ |
| សារណាផ្ទាល់មាត់របស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធទៅនឹងលំដាប់លំដោយនៃការតាំងសំណួរទៅកាន់សាក្សី 2-TCW-960 | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br><br>អង្គជំនុំជម្រះ | ១០.២៣<br>១០.២៤<br>១០.២៨<br>១០.៣០<br>១០.២៨<br>១០.២៩<br>១០.៣០ | ១០.២៤<br>១០.២៨<br>១០.២៩<br>១០.៣០<br>១០.២៨<br>១០.៣០<br>១០.៣១ |
| សារណាផ្ទាល់មាត់លើការដកសាក្សី 2-TCW-960 | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី ខៀវ សំផន<br>អង្គជំនុំជម្រះ | ១០.៣១<br>១០.៣២<br>១០.៣៣<br>១៣.៣២ | ១០.៣២<br>១០.៣២<br>១០.៣៣<br>១៣.៣៤ |
| ការតាំងសំណួរទៅកាន់អ្នកជំនាញ 2-TCE-81 | អង្គជំនុំជម្រះ<br>មេធាវីការពារក្តី ខៀវ សំផន | ១១.១១<br>១៣.៣៤<br>១៥.០៤ | ១១.៣៤<br>១៤.៤១<br>១៦.០១ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន ។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**សារណាផ្ទាល់មាត់របស់សហមេធាវីនាំមុខស្នើសុំឱ្យអង្គជំនុំជម្រះទទួលយក សម្រង់នៃសៀវភៅដែលនិពន្ធដោយអ្នកជំនាញ 2-TCE-81**

អង្គជំនុំជម្រះ បានផ្តល់វេទិកាដល់ភាគីដើម្បីធ្វើសារណាផ្ទាល់មាត់ទៅលើសំណើរបស់សហមេធាវីនាំមុខ ដែលបានស្នើសុំឱ្យទទួលយកជាភ័ស្តុតាងនូវសម្រង់នៃសៀវភៅដែលនិពន្ធដោយអ្នកជំនាញ 2-TCE-81 ដែលមានចំណងជើងថា "សេចក្តីស្នេហា និងភាពភ័យខ្លាចនៅក្នុងប្រទេសកម្ពុជា"។ មិនមានភាគីណាមួយជំទាស់ទៅនឹងសំណើនេះទេ ហើយសហព្រះរាជអាជ្ញាបានលើកឡើងថាសៀវភៅទាំងមូលគួរត្រូវបានទទួលយក។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថាការទទួលយកសៀវភៅទាំងមូលគឺមិនមែនជាការចាំបាច់នោះទេ។

អង្គជំនុំជម្រះបានអនុញ្ញាតិតាមសំណើ ហើយទទួលយកសៀវភៅនោះទាំងមូលជាឯកសារភ័ស្តុតាង និងបានដាក់លេខឯកសារជា E3/10677។

**សារណាផ្ទាល់មាត់របស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួនពីរពាក់ព័ន្ធនឹងអ្នកជំនាញ 2-TCE-81**

អង្គជំនុំជម្រះ បានផ្តល់វេទិកាដល់ភាគីដើម្បីធ្វើសារណាផ្ទាល់មាត់ទៅលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលបានស្នើសុំឱ្យទទួលយកជាភ័ស្តុតាងនូវឯកសារចំនួន ពីរ ពាក់ព័ន្ធនឹងអ្នកជំនាញ 2-TCE-81។ ក្នុងអំឡុងពេលសវនាការ មេធាវីការពារក្តីបានកំណត់សំណើរបស់ខ្លួនត្រឹមតែ ស្នើឱ្យអង្គជំនុំជម្រះទទួលយកតែ ពីរ ទំព័រ តែប៉ុណ្ណោះ នូវមតិយោបល់របស់អ្នកជំនាញ ( គឺ ERNs 01330847 និង 01330848)។ មិនមានភាគីណាមួយជំទាស់ទៅនឹងសំណើនេះទេ។

អង្គជំនុំជម្រះបានអនុញ្ញាតិតាមសំណើ ហើយទទួលយកឯកសារចំនួន ពីរ ទំព័រ និងបានដាក់លេខឯកសារ E3/10676។

**សារណាផ្ទាល់មាត់របស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធទៅនឹងលំដាប់លំដោយនៃការតាំងសំណួរទៅកាន់សាក្សី 2-TCW-960 និង សារណាផ្ទាល់មាត់លើការដកសាក្សី 2-TCW-960**

អង្គជំនុំជម្រះ បានផ្តល់វេទិកាដល់ភាគីដើម្បីធ្វើសារណាផ្ទាល់មាត់ទៅលើសំណើរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងលំដាប់លំដោយនៃការតាំងសំណួរទៅកាន់សាក្សី 2- TCW-960។ មេធាវីការពារក្តីបានលើកឡើងថាខ្លួនស្នើសុំដកសំណើដែលបានសុំកោះហៅសាក្សី 2-TCW-960។ អង្គជំនុំជម្រះបានផ្តល់វេទិកាដល់ភាគីដើម្បីធ្វើសារណាលើសំណើរបស់មេធាវីការពារក្តី នួន ជា ដែលបានសុំដកសាក្សី 2-TCW-960។

អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់ រក្សានូវសេចក្តីសម្រេចរបស់ខ្លួនក្នុងការស្តាប់សាក្សី 2-

TCW-960 ដូចដែលបានកំណត់។

<u>ការតាំងសំណួរទៅកាន់អ្នកជំនាញ 2-TCE-81</u>

អង្គជំនុំជម្រះ ហើយបន្ទាប់មក មេធាវីការពារក្ដី ខៀវ សំផន បានតាំងសំណួរទៅកាន់អ្នកជំនាញ។

New E3s

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Clas s | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1067 6 | | 01330847 01330848 | FINAL Submission of Transcripts for Court Review Peg LeVine (23 September 2015) | P | / | / | / |
| E3/1067 7 | | 01334888-01335002 | LeVine, Peg (2010). Love and Dread In Cambodia | P | / | / | / |

## Reclassified Document

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1794 | | 00894147-00894148<br>00806213-00806229<br>00834033-00834042<br>00806213-00806219<br><br>00482421-00482714<br><br>00809683-00809686<br>00821550-00821553<br>00822186-00822189<br>00950454-00950457 | Peg LeVine, "A Contextual Study into the Wedding and Births under the Khmer Rouge" | P | 00894148 | 00482443<br>00482430<br>00482481<br>00482538 | 00950456 |
| E29/489/1 | | 01331002-01331003<br>01331001-01331001 | Trial Chamber Memorandum Entitled "Response of Rob Lemkin to TC Inquiry". | P | / | / | / |

## Other Documents

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4202 | | 00858214-00858410<br>00920122-00920144<br><br>00757471-00757568<br><br>00849349-00849484 | Book by GINA Chon and THET Sambath | P | / | / | / |

| **ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖** |
|---|
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។<br>• សម្រេចទទួលយកសៀវភៅដែលនិពន្ធដោយអ្នកជំនាញ 2-TCE-81 ជាឯកសារភ័ស្តុតាង ហើយបានដាក់លេខឯកសារ E3/10677 ។<br>• សម្រេចទទួលយកទំព័រដែលពាក់ព័ន្ធដែលមានលេខ ERNs 01330847 និង 01330848 ហើយបានដាក់លេខឯកសារ E3/10676 ។<br>• សម្រេចរក្សាសេចក្តីសម្រេចក្នុងការកោះហៅសាក្សី 2-TCW- 960 ដូចបានកំណត់ ទោះបីជាមានសំណើសុំដកសាក្សីក៏ដោយ។<br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ ។ |

| **កាលវេលាសវនាការបន្ត** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

កញ្ញា ជា ស៊ីវ... កញ្ញា Stavroula PAPADOPOULOS